# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

សំណុំរឿងព្រហ្មទណ្ឌ លេខ: ១១៤ អក
ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧
សាលក្រមលេខ: ៦៥ (ឃ)
ថ្ងៃទី០១ ខែមេសា ឆ្នាំ២០២១

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្ដាល

-បានបើកសវនាការជំនុំជម្រះជាសាធារណៈ នៅសាលាដំបូងខេត្តកណ្ដាល នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២១ ដោយមាន សមាសភាពដូចតទៅ:

**ចៅក្រមជំនុំជម្រះ**

លោកស្រី [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារង អមសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជី សាលាដំបូងខេត្តកណ្ដាល

**ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ: ១១៤ អក ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ ដែល**មានសាវតាជាតិជនជាប់ចោទដូចខាងក្រោម ៖

១-ឈ្មោះ [redacted] ចន្ធូ ភេទប្រុស អាយុ ៤៨ឆ្នាំ ជនជាតិខ្មែរ មុខរបររត់ម៉ូតូឌុប ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូ[redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] អេង (រ) ម្ដាយឈ្មោះ [redacted] អុត (រ) ប្រពន្ធឈ្មោះ [redacted] ស្រីពៅ មានកូន ០៣នាក់ ទោសពីមុនគ្មាន (រ) ។ (ក្រៅឃុំ)

២-ឈ្មោះ [redacted] សុភា ភេទប្រុស អាយុ ៥៦ឆ្នាំ ជនជាតិខ្មែរ មុខរបរមេភូមិអញ្ចែងលើ ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តបាត់ដំបង ទីលំនៅបច្ចុប្បន្ននៅភូមិអញ្ចែងលើ ឃុំពុកឬស្សី ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] កែម (ស) ម្ដាយឈ្មោះ [redacted] ឯមម៉ារ៉េត (ស) ប្រពន្ធឈ្មោះ [redacted] គឹមឃិន មានកូន ០៦នាក់ ទោសពីមុនគ្មាន (រ) ។ (ក្រៅឃុំ)

៣-ឈ្មោះ [redacted] លីឡេង ភេទប្រុស អាយុ ៧១ឆ្នាំ ជនជាតិខ្មែរ មុខរបរ មេឃុំពុកឬស្សី ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តកណ្ដាល ទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] អាំងលី (ស) ម្ដាយឈ្មោះ [redacted] តាំងគួយ (ស) ប្រពន្ធឈ្មោះ [redacted] គឹមហោ មានកូន ០៧នាក់ ទោសពីមុនគ្មាន (រ) ។ (ក្រៅឃុំ)

៤-ឈ្មោះ [redacted] អុន ភេទប្រុស អាយុ ៥៩ឆ្នាំ ជនជាតិខ្មែរ មុខរបរមេភូមិអញ្ចែងក្រោម ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] សាត់ (ស) ម្ដាយឈ្មោះ [redacted] លុយ (ស) ប្រពន្ធឈ្មោះ [redacted] ចាយ មានកូន ០៣នាក់ ទោសពីមុនគ្មាន (រ) ។ (ក្រៅឃុំ)



Scanned with CamScanner

ដោយមានមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] អុន ។

ដោយមានមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ចន្ទូ , ឈ្មោះ [redacted] អុន , ឈ្មោះ [redacted] សុភា និងឈ្មោះ [redacted] លីឡេង ។

ជាប់ចោទពីបទៈ សមគំនិតក្នុងអំពើឆបោក ប្រព្រឹត្តនៅភូមិអំពែងលើ ឃុំពុកឫស្សី ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីអំឡុងខែវិច្ឆិកា ឆ្នាំ២០១៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩ , មាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុខឃាង ភេទប្រុស អាយុ ៤៤ឆ្នាំ ជនជាតិខ្មែរ មុខរបរ សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យន័រតុង មានទីកន្លែងកំណើតនៅភូមិព្រែកសណ្តែក ឃុំព្រែកចង្ក្រាន ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង ទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ ១២៩ អឺ០ ផ្លូវ១១០ ភូមិ៤ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] សុខលី (រ) ម្តាយឈ្មោះ [redacted] ស្រ៊ាង (រ) ប្រពន្ធឈ្មោះ [redacted] កាមាឡា មានកូន ០១នាក់ ។

ដោយមានមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុខឃាង។

## ៦អង្គហេតុមានដូចតទៅ

កាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៤ នៅចំណុចភូមិអំពែងលើ ឃុំពុកឫស្សី ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ឈ្មោះ [redacted] អៀង , ឈ្មោះ [redacted] ឌឿន , ឈ្មោះ [redacted] ហឿន និងគូកន បានអះអាងថា ខ្លួនជាម្ចាស់ដីទំហំ ៣០ ហិចតា ដែលមានទីតាំងស្ថិតនៅភូមិអំពែងលើ ឃុំពុកឫស្សី ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ដោយមានភ្ជាប់មកជាមួយប្លង់បង្ហាញទីតាំងដី ដែលមានផ្តិតមេដៃម្ចាស់ដី និងទទួលស្គាល់ពីអាជ្ញាធរឃុំពុកឫស្សី បានលក់ដីក្នុងតម្លៃ ៥,៥ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដែលមានទឹកប្រាក់សរុបចំនួន ១,៦៥០,០០០ $ (មួយលានប្រាំមួយសែនប្រាំម៉ឺនដុល្លារអាមេរិក) ឱ្យទៅឈ្មោះ [redacted] សុខឃាង ហើយបាននាំឈ្មោះ [redacted] សុខឃាង ទៅចង្អុលបង្ហាញទីតាំងដី ។ ដោយមានការជឿទុកចិត្តឈ្មោះ [redacted] សុខឃាង បានចុះកិច្ចសន្យាទិញលក់ខាងលើ និងបានកក់ប្រាក់ និងប្រគល់ប្រាក់ជាបន្តបន្ទាប់សរុបចំនួន ៩៥០,០០០ $ (កៅសិបប្រាំបួនម៉ឺនដុល្លារអាមេរិក) ឱ្យទៅឈ្មោះ [redacted] ឌឿន ឈ្មោះ [redacted] អៀន និងឈ្មោះ [redacted] ហឿន ។ ក្រោយមកអ្នកទាំង ០៣នាក់នេះ បានរួមគំនិតជាមួយឈ្មោះ [redacted] សុខទ្រី ក្រោយមកឈ្មោះ [redacted] លីឡេង , ឈ្មោះ [redacted] សុភា , ឈ្មោះ [redacted] ចន្ទូ និងឈ្មោះ [redacted] អុន បានបន្លំប្តូរទីតាំងថ្មី និងរូបរាងថ្មី ហើយរៀបចំល្បិចបញ្ឆោតឈ្មោះ [redacted] សុខឃាង ជំរុញឱ្យទទួលយកទីតាំងថ្មី ។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ១២២៤ ដកសព ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល ដែលប្តឹងសុំឱ្យចៅក្រមស៊ើបសួរ បញ្ជូនជនត្រូវចោទឈ្មោះ [redacted] ចន្ទូ ភេទប្រុស អាយុ ៤៤ឆ្នាំ , ឈ្មោះ [redacted] សុភា ភេទប្រុស អាយុ ៥៦ឆ្នាំ , ឈ្មោះ [redacted] លីឡេង ភេទប្រុស អាយុ ៧១ឆ្នាំ និងឈ្មោះ [redacted] អុន ភេទប្រុស អាយុ ៥៩ឆ្នាំ ទៅជំនុំជម្រះ ។

បានឃើញ ដីកាដំណោះស្រាយលេខ ១២៨៧ ដកដស ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរ សាលាដំបូងខេត្តកណ្តាល ដែលសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ [redacted] ចន្ទូ ភេទប្រុស អាយុ ៤៤ឆ្នាំ ជនជាតិខ្មែរ , ឈ្មោះ [redacted] សុភា ភេទប្រុស អាយុ ៥៦ឆ្នាំ ជនជាតិខ្មែរ , ឈ្មោះ [redacted] លីឡេង ភេទប្រុស អាយុ ៧១ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] អុន ភេទប្រុស អាយុ ៥៩ឆ្នាំ



Scanned with CamScanner

ជនជាតិខ្មែរ ទៅជំនុំជម្រះ ពីបទៈ សមគំនិតក្នុងអំពើឆបោក ប្រព្រឹត្តនៅភូមិអញ្ចែងលើ ឃុំពុកឫស្សី ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីអំឡុងខែវិច្ឆិកា ឆ្នាំ២០១៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩ , មាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

## នាពេលសវនាការ

-អំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] ចន្ទូ នៅដំណាក់កាលតំណាងអយ្យការ បានឆ្លើយថា មូលហេតុដែលខ្លួនបានចូលគ្រប់សកម្មភាពទិញលក់ដីជាមួយឈ្មោះ [redacted] សុខទ្រី ពីព្រោះឈ្មោះ [redacted] សុខទ្រី បានឱ្យលុយខ្លួនចាយខ្លះដែរម្តង ២០០០០ $ (ពីរម៉ឺនដុល្លារអាមេរិក) ទៅ ១០០០០០ $ (ដប់ម៉ឺនដុល្លារអាមេរិក) ហើយខ្លួនបានគិតថាឈ្មោះ [redacted] សុខទ្រី មានការងារឱ្យខ្លួនធ្វើក្រែងបានភាគរយខ្លះ ។ ឈ្មោះ [redacted] សុខទ្រី បានឱ្យលុយខ្លួនម្តង ១០ $ (ដប់ដុល្លារអាមេរិក) ទៅ ២០ $ (ម្ភៃដុល្លារអាមេរិក) ។ ខ្លួនមិនមានទំនាក់ទំនងជិតស្និតជាមួយឈ្មោះ [redacted] សុខទ្រី នោះទេ ទើបតែឈ្មោះ [redacted] សុខឃាង ចុះទៅទិញដី ទើបខ្លួនដើរជាមួយឈ្មោះ [redacted] សុខទ្រី ក្រែងបានប្រយោជន៍ខ្លះ ។ ខ្លួនបានស្គាល់ឈ្មោះ [redacted] ឌឿន , ឈ្មោះ [redacted] ហឿន , ឈ្មោះ [redacted] អៀង តាមរយៈឈ្មោះ [redacted] សុខទ្រី ចំណែកអ្នកដែលតែងតែឱ្យលុយខ្លួន គឺឈ្មោះ [redacted] សុខទ្រី ។ ខ្លួនបានដឹងថាឈ្មោះ [redacted] សុខឃាង បានកក់លុយចំនួន ០៣លើក ស្មើនឹង ៦០ ភាគរយ ឱ្យទៅឈ្មោះ [redacted] ហឿន , ឈ្មោះ [redacted] ឌឿន , ឈ្មោះ [redacted] អៀង ហើយខ្លួនក៏បានចូលរួមទៅមើលការទទួលលុយប្រគល់លុយដែរ ។ ខ្លួនបានឮតាមរយៈឈ្មោះ [redacted] សុខទ្រី ថា ការប្តូរដីពីទីតាំងទី ១ មកទីតាំងទី ២ ឈ្មោះ [redacted] សុខឃាង ក៏យល់ព្រមដែរ ។ ចំពោះបញ្ហាដែលឈ្មោះ [redacted] សុខឃាង មិនព្រមប្រគល់លុយចំនួន ៤០ ភាគរយ នោះគឺខ្លួនបានដឹងតាមរយៈឈ្មោះ [redacted] សុខទ្រី មកប្រាប់ខ្លួនថា ឈ្មោះ [redacted] សុខឃាង បានសុំចុះតម្លៃដី ចំនួនមួយដុល្លារក្នុងមួយម៉ែត្រការ៉េ ហើយភាគីអ្នកលក់មិនព្រមក៏កើតមានរឿងខាងលើតែម្តង ។

-អំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] អុន នៅដំណាក់កាលតំណាងអយ្យការបានឆ្លើយថា នៅអំឡុងឆ្នាំ២០១៤ ខ្លួនទៅចុះវាស់វែងដីនៅភូមិអញ្ចែងលើ ចំនួន ០៤ ហិចតា ដែលដីជាកម្មសិទ្ធិរបស់ប្រជាជននៅភូមិអញ្ចែងក្រោម មានអ្នកទិញឈ្មោះ [redacted] អៀង ដោយមានកិច្ចសន្យាលក់ទិញ ហើយខ្លួនក៏បានចុះហត្ថលេខាលើកិច្ចសន្យាទិញលក់ខាងលើផងដែរ ។ ខ្លួនមិនបានដឹងរឿងដែលឈ្មោះ [redacted] អៀង លក់ដីឱ្យឈ្មោះ [redacted] សុខឃាង នោះទេ ។ ខ្លួនមិនស្គាល់ឈ្មោះ [redacted] សុខឃាង នោះទេ ហើយការទិញលក់ដីជាមួយគាត់យ៉ាងមិចនោះ ខ្លួនក៏មិនបានដឹងដែរ ។ ខ្លួនទទួលស្គាល់ថា គំនូសប្លង់បង្ហាញទ្រង់ទ្រាយដីចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៥ គឺខ្លួនពិតបានចុះហត្ថលេខា ខ្លួនសូមបញ្ជាក់ថា ការចុះហត្ថលេខារបស់ខ្លួននេះ គឺចង់បញ្ជាក់ថា ប្រជាពលរដ្ឋ ដែលមានទីតាំងនៅភូមិអញ្ចែងក្រោម គាត់មានដីនៅភូមិអញ្ចែងលើ ។ ចំពោះអង្គហេតុនេះខ្លួនមិនបានចូលរួមប្រព្រឹត្តអំពើណាមួយដែលខុសច្បាប់ សកម្មភាពរបស់ខ្លួន គឺធ្វើក្នុងនាមអាជ្ញាធរមូលដ្ឋាន ។

-អំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុភា នៅដំណាក់កាលតំណាងអយ្យការបានឆ្លើយថា នៅអំឡុងឆ្នាំ២០១៥ ខ្លួនដឹងថាឈ្មោះ [redacted] សុខឃាង បានចុះទៅមើលព្រំដីនៅភូមិអញ្ចែងលើ ហើយខ្លួនក៏បានចូលរួមដែរក្នុងនាមខ្លួនជាមេភូមិអញ្ចែងលើ ។ ខ្លួនមិនបានដឹងពីបញ្ហាអ្វីផ្សេងទេ គ្រាន់តែបានដឹងថា នៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៥ ភាគីអ្នកលក់ដែលមានឈ្មោះ [redacted] អៀង ដែលមានអ្នកទិញឈ្មោះ [redacted] សុខឃាង ព្រមទាំងសាក្សីអ្នកផ្ទេរសិទ្ធិមានឈ្មោះ [redacted] ឌឿន និងឈ្មោះ [redacted] ហឿន រីឯសាក្សីអ្នកទទួលសិទ្ធិមានឈ្មោះ [redacted] សុខទ្រី ហើយខ្លួនក៏បានចូលរួមដែរក្នុងនាមខ្លួនជាមេភូមិ



Scanned with CamScanner

និងបានបញ្ជាក់ទៅលើលិខិតផ្ទេរសិទ្ធិខាងលើផងដែរ ។ ចំពោះការចរចារកិច្ចសន្យារវាងអ្នកលក់ និងអ្នកទិញ ខ្លួនមិនបានដឹងទេ ហើយក៏មិនបានចូលរួមដែរ ។ ចំពោះបញ្ហាអ្វីផ្សេងទៀត ខ្លួនមិនបានដឹងទេ ។ ខ្លួនបានដឹងថា ដីដែលមានទីតាំងស្ថិតនៅភូមិអញ្ចេងលើ ឃុំពុកឫស្សី ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ឈ្មោះ [redacted] ឌឿន , ឈ្មោះ [redacted] ហឿន , ឈ្មោះ [redacted] អៀង បានទិញពីប្រជាជន ហើយយកមកលក់បន្តឱ្យឈ្មោះ [redacted] សុខឃាង ។ ចំពោះការចុះហត្ថលេខា និងប្រថាប់ត្រាលើលិខិតផ្សេងៗខាងលើ គឺខ្លួនបានធ្វើទៅតាមការព្រមព្រៀងរបស់គូភាគីអ្នកលក់ និងអ្នកទិញ និងក្នុងនាមជាអាជ្ញាធរ ខ្លួនមិនបានចូលរួមសមគំនិតជាមួយឈ្មោះ [redacted] ឌឿន , ឈ្មោះ [redacted] ហឿន និងឈ្មោះ [redacted] អៀង ក្នុងអំពើឆបោកនោះទេ ។

-អំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] លីឡេង នៅដំណាក់កាលតំណាងអយ្យការបានឆ្លើយថា នៅឆ្នាំ២០១៤ ខ្លួនបានដឹងថា ឈ្មោះ [redacted] សុខឃាង បានទិញដីពីប្រជាពលរដ្ឋ តាមរយៈឈ្មោះ [redacted] ឌឿន , ឈ្មោះ [redacted] ហឿន និងឈ្មោះ [redacted] អៀង ស្ថិតនៅក្នុងភូមិអញ្ចេងលើ ទំហំ ៣០ ហិចតា ចំពោះតម្លៃ ខ្លួនមិនបានដឹងទេ ។ ចំពោះបញ្ហា ចរចារតម្លៃដីខ្លួនមិនបានដឹងទេ ខ្លួនគ្រាន់តែបានដឹងថានៅក្នុងកិច្ចសន្យាដីមានតម្លៃ ៥,៥ $ ក្នុងមួយម៉ែត្រការ៉េ ហើយក្នុងនាមជាមេឃុំ ខ្លួនក៏បានចុះហត្ថលេខា ប្រថាប់ត្រាបញ្ជាក់នៅលើកិច្ចសន្យាទិញលក់ដីរវាងឈ្មោះ [redacted] សុខឃាង និងឈ្មោះ [redacted] ឌឿន , ឈ្មោះ [redacted] អៀង , និងឈ្មោះ [redacted] ហឿន ។ ខ្លួនបញ្ជាក់ថា ដីដែលមានទីតាំងស្ថិតនៅភូមិអញ្ចេងលើ ឃុំពុកឫស្សី ពិតជាដីរបស់ប្រជាជន ពិតប្រាកដមែន ដូចមានក្នុងលិខិតបញ្ជាក់ទីតាំងចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៤ ។ ក្រោយមកទៀត បន្ទាប់ពីមានការព្រមព្រៀងទិញលក់ដី រវាងអ្នកទិញ និងអ្នកលក់ ខ្លួនសូមបញ្ជាក់ថា ដីដែលមានទីតាំងស្ថិតនៅភូមិអញ្ចេងលើ ប្រជាជនលក់មកឱ្យឈ្មោះ [redacted] ឌឿន , ឈ្មោះ [redacted] ហឿន និងឈ្មោះ [redacted] អៀង ។ បន្ទាប់ពីមានការទិញលក់ដីហើយ ក៏មានការប្រគល់ដីឱ្យទៅឈ្មោះ [redacted] សុខឃាង ហើយដីដែលប្រគល់នោះ គឺស្ថិតនៅក្នុងភូមិអញ្ចេងលើ ឃុំពុកឫស្សី ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ប្រមាណ ៣១៦៥០ ម៉ែត្រការ៉េ ។ ខ្លួនសូមបញ្ជាក់បន្ថែមថា ដីដែលមានគំនូសបង្ហាញទីតាំងដីចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៥ គឺគូសតាមលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីទាំងប្រាំមួយច្បាប់ ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីលេខ ៣៦៣ ប.ជ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ របស់អភិបាលស្រុកខ្សាច់កណ្ដាល លិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីលេខ ៤៩៤ ប.ជ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥ របស់អភិបាលស្រុកខ្សាច់កណ្ដាល លិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីលេខ ៣៥៥ ប.ជ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៥ របស់អភិបាលស្រុកខ្សាច់កណ្ដាល លិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីលេខ ៣៥៦ ប.ជ ចុះថ្ងៃ០២ ខែមីនា ឆ្នាំ២០១៥ របស់អភិបាលស្រុកខ្សាច់កណ្ដាល , លិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីលេខ ៣៥៧ ប.ជ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៥ របស់អភិបាលស្រុកខ្សាច់កណ្ដាល , លិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីលេខ ៤៩៧ ប.ជ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៥ របស់អភិបាលស្រុកខ្សាច់កណ្ដាល ហើយដីទាំងនេះស្ថិតនៅភូមិអញ្ចេងលើទាំងអស់ ។ ចំពោះហត្ថលេខាមេភូមិអញ្ចេងក្រោម ចុះហត្ថលេខាបញ្ជាក់ទៅលើគំនូសបង្ហាញចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៥ គឺគ្រាន់តែបញ្ជាក់ថា ប្រជាជនដែលមានទីលំនៅនៅភូមិអញ្ចេងក្រោម គាត់មានដីនៅភូមិអញ្ចេងលើដែរ ។ ខ្លួនចុះហត្ថលេខា និងប្រថាប់ត្រា បញ្ជាក់លើកិច្ចសន្យាទិញលក់ដី . ប្លង់គំនូសបង្ហាញទីតាំងដីនៅភូមិអញ្ចេងលើ ឃុំពុកឫស្សី ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៤ និងគំនូសបង្ហាញទ្រង់ទ្រាយដីរបស់ឈ្មោះ [redacted] សុខឃាង ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៥ ព្រមទាំងលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីស្ថិតនៅភូមិ



Scanned with CamScanner

អព្វែងលើ ឃុំពុកឫស្សី ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល សរុបទាំងអស់ទំហំ ៣១៦៥០០ ម៉ែត្រការ៉េ នៅអំឡុងឆ្នាំ២០១៥ ប្រាកដមែន ។

-អំណានចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុខឃាង នៅដំណាក់កាលតំណាងអយ្យការ បានឆ្លើយថា កាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ឈ្មោះ [redacted] អៀង , ឈ្មោះ [redacted] ឌឿន , ឈ្មោះ [redacted] ហឿន និងគូកន បានអះអាងថា ខ្លួនជាម្ចាស់ដី និងបានលក់ស្ថិតនៅក្នុងភូមិអព្វែងលើ ឃុំពុកឫស្សី ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ទំហំ ៣០ ហិចតា ដោយបានភ្ជាប់មកជាមួយនូវប្លង់បង្ហាញទីតាំងដី មានផ្ដិតមេដៃម្ចាស់ដី និងទទួលស្គាល់ពីអាជ្ញាធរឃុំពុកឫស្សី ក្នុងតម្លៃ ៥,៥ ដុល្លារអាមេរិក ក្នុងមួយម៉ែត្រក្រឡា ដែលមានទឹកប្រាក់សរុបចំនួន ១,៦៥០,០០០ $ (មួយលានប្រាំមួយសែនប្រាំម៉ឺនដុល្លារមេរិក) មកឱ្យខ្លួន ហើយបាននាំខ្លួនទៅចង្អុលបង្ហាញទីតាំងដីទៀតផង ។ បន្ទាប់ពីបានពិនិត្យឯកសារ និងទីតាំងដីរួចមក ខ្លួនបានចុះកិច្ចសន្យាទិញលក់ និងកក់ប្រាក់ចំនួន ៣៣០០០០ $ (សាមសិបបីម៉ឺនដុល្លារអាមេរិក) ឱ្យទៅឈ្មោះ [redacted] ឌឿន , ឈ្មោះ [redacted] អៀង និងឈ្មោះ [redacted] ហឿន ហើយខ្លួនបានប្រគល់ប្រាក់ជាបន្តបន្ទាប់ដើម្បីរៀបចំសំណុំឯកសារ និងផ្ដិតមេដៃលើឯកសារផ្ទេរសិទ្ធិកាន់កាប់ ដែលមានទឹកប្រាក់សរុប ៩៩០០០០ $ (កៅសិបប្រាំបួនម៉ឺនដុល្លារអាមេរិក) ។ ក្រោយមកឈ្មោះ [redacted] លីឡេង , ឈ្មោះ [redacted] សុភា , ឈ្មោះ [redacted] ចន្ធូ និងឈ្មោះ [redacted] អុន បានរៀបចំសមគំនិតជាមួយឈ្មោះ [redacted] សុខទ្រី និងសហការជាមួយឈ្មោះ [redacted] ឌឿន , ឈ្មោះ [redacted] ហឿន , ឈ្មោះ [redacted] អៀង ដែលតាំងខ្លួនជាម្ចាស់ដី ដោយបន្លំប្ដូរទីតាំងដីថ្មី ខុសពីទីតាំងដើម និងរូបរាងដី ហើយបានរៀបចំប្រើល្បិចបោកបញ្ឆោតលួងលោមឱ្យខ្លួនជាអ្នកទិញទទួលយកដីទីតាំងថ្មីនេះ ដែលជាហេតុធ្វើឱ្យខ្លួនខូចខាតប្រយោជន៍ជាច្រើន ។ ការដែលខ្លួនបានធ្វើកិច្ចសន្យាទិញលក់ជាមួយឈ្មោះ [redacted] ឌឿន , ឈ្មោះ [redacted] អៀង , ឈ្មោះ [redacted] ហឿន នេះដោយមានការអះអាងពីឈ្មោះ [redacted] លីឡេង ថាដីខាងលើស្ថិតក្នុងទីតាំងតែមួយ ហើយជាកម្មសិទ្ធិរបស់អ្នកទាំងបី ជាហេតុធ្វើឱ្យខ្លួនជឿទុកចិត្ត ។ ក្រោយមកខ្លួនបានចុះទៅមើលដីម្ដងទៀត ស្រាប់តែឃើញដីខាងលើមានទីតាំងខុសគ្នា ចំណែករូបរាងដីក៏ខុសគ្នាដែរ ។ នៅក្នុងដំណាក់កាលសាលាឧទ្ធរណ៍ មេធាវីការពារឱ្យជនជាប់ចោទបានឆ្លើយទទួលស្គាល់ថាដីទាំងពីរខាងលើពិតជាមានទីតាំងខុសគ្នាមែន ។ ក្រោយមក នៅថ្ងៃទី៦ ខែមករា ឆ្នាំ២០១៧ ក្រុមការងារសាលាឧទ្ធរណ៍បានចុះពិនិត្យដីនៅភូមិអព្វែងលើ ឃុំពុកឫស្សី ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ជាលទ្ធផលឃើញថា ដីទាំងពីរខាងលើពិតជាមានទីតាំងខុសគ្នាមែន ។ ខ្លួនសូមបញ្ជាក់ថា បន្ទាប់ពីខ្លួនបានកក់ប្រាក់ឱ្យឈ្មោះ [redacted] ឌឿន , ឈ្មោះ [redacted] ហឿន , ឈ្មោះ [redacted] អៀង បានចំនួន ៦០ ភាគរយ ស្មើនឹង ៩៩០០០០ $ (កៅសិបប្រាំបួនម៉ឺនដុល្លារអាមេរិក) គឺលោក [redacted] លីឡេង ជាមេឃុំ និងឈ្មោះ [redacted] សុភា ជាមេភូមិ បានចុះហត្ថលេខា និងប្រថាប់ត្រា នៅដីទីតាំងថ្មី ខុសពីដីដែលបានលក់ឱ្យខ្លួនក្នុងកិច្ចសន្យា ។ ឈ្មោះ [redacted] លីឡេង ក្នុងឋានៈជាមេឃុំ នៅតែអះអាងដោយទុច្ចរិត ដូចមាននៅក្នុងកំណត់ហេតុសួរចម្លើយលើសំណុំរឿងព្រហ្មទណ្ឌលេខ ២៤៥ អក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥ ហើយឈ្មោះ [redacted] លីឡេង នៅតែអះអាងជាថ្មីនៅចំពោះមុខចៅក្រមស៊ើបសួរ [redacted] ថាទីតាំងដីលក់នោះ និងដីអ្នកកក់បានចង្អុលបង្ហាញពីដំបូង គឺស្ថិតក្នុងទីតាំងតែមួយទេ ចំណែកឈ្មោះ [redacted] សុភា ក៏អះអាងដូចគ្នានិងលោក [redacted] លីឡេង ដែរថា ចំពោះរឿងនេះអ្នកលក់ទាំងបីនាក់ ពុំបានផ្លាស់ប្ដូរទីតាំងដីដែលលក់នេះទេ គឺនៅទីតាំងដដែល ។ ចំពោះឈ្មោះ [redacted] ចន្ធូ គឺទីតាំងពីដំបូងឈ្មោះ [redacted] ចន្ធូ និងឈ្មោះ [redacted] សុខទ្រី បានព្យាយាមបញ្ចុះបញ្ចូលលួងលោមបញ្ឆោតឱ្យខ្លួនទៅទិញដីស្ថិតនៅភូមិអព្វែងលើ ឃុំពុក



Scanned with CamScanner

ឬស្សី (ទីតាំងចាស់) លុះដល់ថ្ងៃត្រូវប្រគល់ដីមកឱ្យខ្លួនស្រាប់តែឈ្មោះនេះមកប្រគល់ដីខុសពីទីតាំងដើម គឺស្ថិតនៅភូមិអញ្ចែងលើ និងភូមិអញ្ចែងក្រោម ឃុំពុកឬស្សី ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ទៅវិញ (ដីទីតាំងថ្មី) ។ រាល់ពេលក្រុមការងារចុះពិនិត្យដីឈ្មោះ [redacted] ចន្ធូ នេះតែងតែមានវត្តមានចង្អុលម្តងដីដែលមានទីតាំងនៅភូមិអញ្ចែងលើ ម្តងនៅភូមិអញ្ចែងលើ និងភូមិអញ្ចែងក្រោម ហើយដីទាំងពីរនេះមានចម្ងាយប្រហែល ១៥០ ម៉ែត្រពីគ្នា ។ យោងលិខិតសុំបំភ្លឺចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៥ របស់លោក [redacted] ហឿន ក៏បញ្ជាក់ថា ដីក្នុងកិច្ចសន្យាលក់ និងប្លង់ដីថ្មី គឺស្ថិតនៅក្នុងទីតាំងខុសគ្នាពិតប្រាកដមែន ដោយមានបញ្ជាក់ហត្ថលេខា និងត្រា របស់មេភូមិ និងមេឃុំផងដែរ ។ ចំពោះឈ្មោះ [redacted] អុន ជាមេភូមិអញ្ចែងក្រោម ដំបូងឡើយឈ្មោះ [redacted] អុន បានបញ្ជាក់ថាដីដែលខ្លួនបានទិញស្ថិតនៅក្នុងភូមិអញ្ចែងលើ មិនមែនភូមិអញ្ចែងក្រោមទេ ហេតុអ្វីនៅលើប្លង់គាត់នៅតែបញ្ជាក់ថា ប្លង់នេះស្ថិតនៅភូមិអញ្ចែងក្រោមដែរ ។

-អំណានចម្លើយសាក្សីឈ្មោះ [redacted] ហាន ហៅ តាហាន បានឆ្លើយថា អំពីដំណើររឿងទិញលក់ដីយ៉ាងណានោះខ្លួនមិនបានដឹងទេ ។ ខ្លួនគ្រាន់តែដឹងថានៅអំឡុងឆ្នាំ២០១៥ នៅថ្ងៃខែមិនចាំ លោកមេភូមិអញ្ចែងលើឈ្មោះ [redacted] សុភា បានឱ្យខ្លួនទៅចូលរួមជាមួយគណៈកម្មការ ដើម្បីធ្វើការវាស់វែងដីទិញលក់ដីនៅភូមិអញ្ចែងលើ ឃុំពុកឬស្សី ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល រវាងអ្នកទិញឈ្មោះ [redacted] សុខឃាង និងអ្នកលក់ឈ្មោះ [redacted] ឌឿន និងឈ្មោះ [redacted] អៀង ។ ខ្លួនសូមបញ្ជាក់ថា រាល់សកម្មភាពដែលខ្លួនបានចូលរួម គឺទៅតាមការណែនាំរបស់លោកមេភូមិអញ្ចែងលើ ក្នុងនាមខ្លួនជាអនុភូមិអញ្ចែងលើ ។ ខ្លួនមិនបានដឹងអំពីដីដែលមាននៅក្នុងកិច្ចសន្យាទិញលក់រវាងឈ្មោះ ចាន់ សុខឃាង និងឈ្មោះ [redacted] ឌឿន , ឈ្មោះ [redacted] អៀង , ឈ្មោះ [redacted] ហឿន យ៉ាងណានោះទេ ខ្លួនដឹងតែពេលដែលលោកមេភូមិអញ្ចែងលើ ឱ្យទៅចូលរួមវាស់វែងគឺខ្លួនក៏ទៅចូលរួម ហើយដីដែលនៅក្នុងកិច្ចសន្យាទិញលក់នោះមានឬមិនមានក៏ខ្លួនមិនបានដឹងដែរ ។

-អំណានចម្លើយសាក្សីឈ្មោះ [redacted] ស៊ីដេក បានឆ្លើយថា ខ្លួនគ្រាន់តែដឹងថា ឈ្មោះ [redacted] សុខឃាង បានទិញដីពីឈ្មោះ [redacted] ហឿន , ឈ្មោះ [redacted] ឌឿន និងឈ្មោះ [redacted] អៀង ។ ខ្លួនបានស្គាល់ឈ្មោះ [redacted] ចន្ធូ ដោយរាល់ពេលឈ្មោះ [redacted] សុខទ្រី មកជួបឈ្មោះ [redacted] សុខឃាង និងចុះពិនិត្យទីតាំងដី គឺមានវត្តមានឈ្មោះ [redacted] ចន្ធូ ជានិច្ច ។

-មេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុខឃាង បានធ្វើសេចក្តីសន្និដ្ឋានថា នៅក្នុងការទិញលក់ គឺឈ្មោះ [redacted] សុខទ្រី គឺជាអ្នកចុះកិច្ចសន្យា ហើយក្នុងនោះ ក៏មានអាជ្ញាធរចូលរួមដែរ ដោយនៅក្នុងដំណាក់កាលទាំងបីនោះ គឺកូនក្តីខ្លួនបានប្រគល់លុយឱ្យត្រឹមត្រូវ ប៉ុន្តែអ្វីដែលកូនក្តីខ្លួនប្តឹងចោទប្រកាន់ និងទាមទារនោះ ដោយសារតែអ្នកទាំង០៤នាក់នេះ បានចូលរួមសមគំនិតដោយចេតនា ក្នុងអំពើឆបោក ព្រោះគាត់បានប្រឆាំងអះអាងថា ទីតាំងដី គឺដូចគ្នាដូចមានគំនូសបែបនេះ ដែលគំនូសដីនេះ គឺឃើញថា ខុសគ្នាជិត ១០០ម៉ែត្រ ហេតុនេះ កូនក្តីខ្លួនមិនសុខចិត្ត ដោយសារតែមានការប្តូរទីតាំងដី ហើយកូនក្តីខ្លួនបានបង់លុយ បីលើកហើយ ទើបចេញលិខិតផ្ទេរសិទ្ធិឱ្យកូនក្តីខ្លួន និងគំនូសប្លង់ ដែលខុសពីគំនូសទីតាំងដីចាស់ ហេតុនេះហើយ ទើបកូនក្តីខ្លួននៅតែទាមទារចោទប្រកាន់លើអ្នកទាំង ០៤នាក់ ដដែល។

-មេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុខឃាង បានធ្វើសេចក្តីសន្និដ្ឋានថា ចំណុចសំខាន់ដែលកូនក្តីខ្លួនប្តឹង គឺអ្នកទាំង០៤នាក់នេះ បានរួមគំនិតគ្នា

ឆបោកជាមួយឈ្មោះ [redacted] ឌឿន, ឈ្មោះ [redacted] អៀង, ឈ្មោះ [redacted] ហឿន និងឈ្មោះ [redacted] សុទ្រី ដើម្បីបន្លំទីតាំងដីរបស់កូនក្តីខ្លួន។ ដំបូង កូនក្តីខ្លួនមានទីតាំងដីពិតប្រាកដ ស្ថិតនៅភូមិអញ្ចែងលើ ឃុំពុកឫស្សី (ដូចគំនូសបង្ហាញប្លង់ ដែលបានលើកបង្ហាញ) ដោយមានការបញ្ជាក់ពីមេឃុំ [redacted] លីឡេង ថា ២៧ ខែ១០ ឆ្នាំ២០១៤ ដីទាំងនោះពិតជាដីរបស់ប្រជាពលរដ្ឋ ពិតប្រាកដមែន ហើយប្លង់ដីលក់ ថ្ងៃទី២៨ ខែ១១ ឆ្នាំ២០១៤ ឱ្យទៅឈ្មោះ [redacted] សុខឃាង ហើយមានស្នាមមេដៃរបស់ឈ្មោះ [redacted] ហឿន, ឈ្មោះ ឌឹម ឌឿន, ឈ្មោះ [redacted] អៀង បញ្ជាក់នៅលើនោះទៀត ប៉ុន្តែក្រោយពេលកូនក្តីខ្លួនបានបង់ទឹកប្រាក់ចំនួន ៩៥០ ០០០ (កៅសិបប្រាំបួនម៉ឺន) ដុល្លារអាមេរិក រួចហើយ ស្រាប់តែចេញប្លង់ទីតាំងដី ផ្សេងទៅវិញ គឺខុសពីទីតាំងដើមប្រហែលជា ១០០ ទៅ១៥០ម៉ែត្រ។ ចំណុចសំខាន់ គឺអ្នកទាំងបួននាក់នេះ មានឈ្មោះ [redacted] ចន្ធូ,ឈ្មោះ [redacted] លីឡេង, ឈ្មោះ [redacted] សុភា និងឈ្មោះ [redacted] អុន បានរួមគំនិតគ្នាជាមួយនឹងបក្ខពួកម្ចាស់ដីឈ្មោះ [redacted] អៀង, ឈ្មោះ [redacted] ហឿន និងឈ្មោះ [redacted] ឌឿន និងឈ្មោះ [redacted] សុទ្រី នោះ ប្តូរទីតាំងដី ហើយរៀបកិច្ចបញ្ឆោតឱ្យឈ្មោះ [redacted] សុខឃាង ព្រមទទួលយកទីតាំងដីនេះ ដែលខុសពីទីតាំងដីចាស់។ នេះជាភស្តុតាងមួយបញ្ជាក់ច្បាស់ហើយថា អ្នកទាំង០៤នាក់នេះ បានរួមគំនិតនៅក្នុងអំពើឆបោក កូនក្តីខ្លួន ហើយចំណែកឯចម្លើយឈ្មោះ [redacted] ចន្ធូ, ឈ្មោះ [redacted] សុភា, ឈ្មោះ [redacted] លីឡេង និងឈ្មោះ [redacted] អុន បានឆ្លើយនៅដំណាក់កាលអយ្យការ គឺខ្លួនជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹង សូមធ្វើការបដិសេធចោល ព្រោះគាត់អះអាងយកត្រូវរៀងខ្លួន ដើម្បីការពារខ្លួនរបស់គាត់ប៉ុណ្ណោះ។ ឆ្លងកាត់តាមការពិភាក្សាដេញដោល និងសិក្សាសំណុំរឿង បានបង្ហាញថា អ្នកទាំង០៤នាក់នេះ ឈ្មោះ [redacted] ចន្ធូ, ឈ្មោះ [redacted] លីឡេង, ឈ្មោះ [redacted] សុភា និងឈ្មោះ [redacted] អុន នេះពិតជាបានឃុបឃិតគ្នាក្នុងអំពើឆបោក ជាមួយឈ្មោះ [redacted] អៀង, ឈ្មោះ [redacted] ឌឿន និងឈ្មោះ [redacted] ហឿន ក៏បានរួមគំនិតជាមួយឈ្មោះ [redacted] សុខទ្រី ដែរ ដោយប្រើល្បិចកលបន្លំប្តូរទីតាំងដីរបស់កូនក្តីខ្លួនពីទីតាំងដើមមកទីតាំងថ្មី ដោយបោកបញ្ឆោតឱ្យកូនក្តីខ្លួនឈ្មោះ [redacted] សុខឃាង ទទួលយកទីតាំងថ្មីដែលខុសពីទីតាំងដើម។ ដូច្នេះ ខ្លួនក្នុងនាមជាមេធាវីការពារក្តី ស្នើសុំចៅក្រមជំនុំជម្រះ ទី១ ផ្តន្ទាទោសជនជាប់ចោទទាំង ០៤នាក់ តាមនីតិវិធីច្បាប់ ជាអតិបរមា ទី២ សុំទាមទារសំណងការខូចខាត និងថ្លៃសំណងការខូចខាត និងថ្លៃសេវាមេធាវីចំនួន ៥ ០០០ ០០០ (ប្រាំលាន) ដុល្លារអាមេរិក និងទី៣ ស្នើសុំលោកស្រីចៅក្រមជំនុំជម្រះ ចេញដីកាចាប់ខ្លួនជនជាប់ចោទទាំង០៤នាក់ នេះយកមកផ្តន្ទាទោសទៅតាមផ្លូវច្បាប់។

-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថាៈ ឆ្លងកាត់ការបើកសវនាការជំនុំជម្រះជាសាធារណៈ លើសំណុំរឿងព្រហ្មទណ្ឌនេះ តំណាងអយ្យការ យល់ឃើញថា កាលពីមុននេះ គឺមានសំណុំរឿងមួយទៀត ដែលមានឈ្មោះ [redacted] អៀង, ឈ្មោះ [redacted] ឌឿន និងឈ្មោះ [redacted] ហឿន គឺត្រូវបានផ្តន្ទាទោសរួចហើយ និងបានចេញដីកាបង្គាប់ឱ្យចាប់ខ្លួន រួចហើយ បន្ទាប់មក រឿងរ៉ាវនេះគឺជាប់បណ្តឹងនៅតុលាការជាន់ខ្ពស់ទៀត។ ក្រោយមកទៀត ដើមបណ្តឹងរដ្ឋប្បវេណី បានប្តឹងបន្ថែមលើអ្នកទាំង០៤នាក់នេះ ដែលមានការពាក់ព័ន្ធនឹងបទសមគំនិតក្នុងការឆបោក។ ដូច្នេះតាមការសួរដេញដោល និងការបើកសវនាការជាសាធារណៈ តំណាងអយ្យការ មិនមានអ្វីបន្ថែមទេ តំណាងអយ្យការនៅតែចោទប្រកាន់លើជនជាប់ចោទទាំង០៤នាក់នេះ គឺមានឈ្មោះ [redacted] អុន, ឈ្មោះ [redacted] លីឡេង, ឈ្មោះ [redacted] សុភា និងឈ្មោះ [redacted] ចន្ធូ គឺអ្នកទាំង០៤នាក់នេះ បានប្រព្រឹត្តនូវសកម្មភាព សមគំនិតក្នុងអំពើឆបោក ប្រព្រឹត្តនៅភូមិអញ្ចែងលើ ឃុំពុកឫស្សី ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីអំឡុងឆ្នាំ២០១៤ ពិតប្រាកដ



Scanned with CamScanner

មែន។ តំណាងអយ្យការ នៅតែរក្សាបទចោទប្រកាន់ តាមដីកាសន្និដ្ឋានស្ថាពរដដែល និងស្នើសុំចៅក្រម
ជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទតាមនីតិវិធីច្បាប់។

មេធាវី [redacted] ជាមេធាវីការពារ
សិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ចន្ទ , ឈ្មោះ [redacted] អុន , ឈ្មោះ [redacted] សុភា និងឈ្មោះ [redacted] លីឡេង
៖ អវត្តមាន។

ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ
ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
ក្រោយពីបានស្តាប់អំណានចម្លើយសាក្សី
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាដំបូងខេត្តកណ្តាល

## យល់ឃើញថា

តាមដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរលេខៈ ១២៨៧ ដកដស ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២០ បានសម្រេចចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] ចន្ទ ភេទប្រុស អាយុ ៤៤ឆ្នាំ ជនជាតិខ្មែរ , ឈ្មោះ [redacted] សុភា ភេទប្រុស អាយុ ៥៦ឆ្នាំ ជនជាតិខ្មែរ , ឈ្មោះ [redacted] លីឡេង ភេទប្រុស អាយុ ៧១ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] អុន ភេទប្រុស អាយុ ៥៩ឆ្នាំ ជនជាតិខ្មែរ ពីបទៈ សមគំនិតក្នុងអំពើឆបោក ប្រព្រឹត្តនៅភូមិអញ្ចែងលើ ឃុំពុកឫស្សី ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីអំឡុងខែវិច្ឆិកា ឆ្នាំ២០១៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩ , មាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

-តាមដីកាសន្និដ្ឋានស្ថាពរលេខ ១២២៤ ដកសព ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល បានសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ [redacted] ចន្ទ ភេទប្រុស អាយុ ៤៤ឆ្នាំ, ឈ្មោះ [redacted] សុភា ភេទប្រុស អាយុ ៥៦ឆ្នាំ, ឈ្មោះ [redacted] លីឡេង ភេទប្រុស អាយុ ៧១ឆ្នាំ និងឈ្មោះ [redacted] អុន ភេទប្រុស អាយុ ៥៩ឆ្នាំ ទៅជំនុំជម្រះ ពីបទ សមគំនិតក្នុងអំពើឆបោក ប្រព្រឹត្តនៅភូមិអញ្ចែងលើ ឃុំពុកឫស្សី ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីអំឡុងខែវិច្ឆិកា ឆ្នាំ២០១៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩ , មាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

-មាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ និយមន័យនៃអ្នកសមគំនិត " ត្រូវចាត់ទុកជាអ្នកសមគំនិតក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិម ចំពោះបុគ្គលណាដែលជួយសម្រួលដោយចេតនា ដល់ការប៉ុនប៉ង ឬការសម្រេចបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ ដោយផ្តល់ជំនួយ ឬការឧបត្ថម្ភរបស់ខ្លួន។

-មាត្រា ៣៧៧ នៃក្រមព្រហ្មទណ្ឌ និយមន័យនៃការឆបោក "អំពើឆបោក គឺជាអំពើបន្លំចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយ ដោយប្រើឈ្មោះក្លែង ដោយអះអាងទៅលើឋានៈក្លែង ដោយរំលោភលើឋានៈពិតប្រាកដ ឬដោយប្រើឧបាយកលទុច្ចរិត ហើយដូច្នេះបានទទួលពីបុគ្គលនេះ ដែលនាំឱ្យខូចប្រយោជន៍របស់បុគ្គលនេះ ឬរបស់តតិយជននូវ ការប្រគល់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ, ការផ្តល់សេវា, ការធ្វើលិខិតដែលមានតម្លៃជាកាតព្វកិច្ច ឬជាការឱ្យរួចពីកាតព្វកិច្ច។

-តាមចម្លើយជនជាប់ចោទ , ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី , ចម្លើយសាក្សី, សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី, ដីកាសន្និដ្ឋានស្ថាពរ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល និងតាមការពិនិត្យឯកសារភស្តុតាងផ្សេងៗទៀតនៅក្នុងសំណុំរឿង បញ្ជាក់ថា តាមសាលក្រមព្រហ្មទណ្ឌលេខ ១១០ (ផជ) ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៦ របស់សាលាដំបូងខេត្តកណ្តាល បានសម្រេចផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] អៀង, ឈ្មោះ [redacted] ហឿន, ឈ្មោះ [redacted] ឌឿន និងឈ្មោះ [redacted] សុខទ្រី ដាក់ពន្ធនាគារកំណត់ចំនួន ០១ (មួយ) ឆ្នាំ ពីបទ ឆបោក ប្រព្រឹត្តនៅភូមិអញ្ចែងលើ ឃុំពុកឬស្សី ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ រួចហើយ។ តាមចម្លើយរបស់ឈ្មោះ [redacted] លីឡេង, ឈ្មោះ [redacted] សុភា និងឈ្មោះ [redacted] អុន បានអះអាងយ៉ាងច្បាស់ដូចគ្នាថា ទីតាំងដីនោះ គឺស្ថិតនៅភូមិអញ្ចែងលើ មិនមែនស្ថិតនៅភូមិអញ្ចែងក្រោម ទេ ប៉ុន្តែបើពិនិត្យតាម គំនូសបង្ហាញទ្រង់ទ្រាយដី (ថ្មី) ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៥ បែរជាទីតាំងដីស្ថិតនៅភូមិអញ្ចែងលើ និងភូមិអញ្ចែងក្រោម ឃុំពុកឬស្សី ទៅវិញ ហើយបើតាមពិនិត្យទៅលើរូបរាងដី គឺមានការខុសគ្នាពី គំនូសទីតាំងដី (ចាស់) ដែលទីតាំងដីចាស់នេះ គឺមានការបញ្ជាក់ថា ស្ថិតនៅភូមិអញ្ចែងលើ ហើយមានក្បាលដី ១០ម៉ែត្រ ជាប់នឹងផ្លូវជាតិលេខ ៣៨០ និងនៅជាប់នោះមានផ្លូវចូលមកខាងក្នុងទំហំ ៣,៥ម៉ែត្រ ទៀត។ នេះសបញ្ជាក់ឱ្យឃើញថា ឈ្មោះ [redacted] លីឡេង, ឈ្មោះ [redacted] សុភា, ឈ្មោះ [redacted] អុន និងឈ្មោះ [redacted] ចន្ទូ បានដឹងច្បាស់ថា ទីតាំងដីថ្មី គឺមិនដូចគ្នានោះទេ ហើយបានរួមគំនិតគ្នាជួយសហការជាមួយឈ្មោះ [redacted] សុខទ្រី និងបក្ខពួក ដើម្បីឆបោកទៅឈ្មោះ [redacted] សុខឃាង ដើម្បីបានចំណែកប្រាក់ចំណេញ។ ជនជាប់ចោទទាំង០៤នាក់ ពិតជាមានចេតនាសម្រួលឱ្យមានការប្តូរទីតាំងដីថ្មី និងរូបរាងដីថ្មី ដើម្បីរៀបចំល្បិចបោកបញ្ឆោតឈ្មោះ [redacted] សុខឃាង ដោយជំរុញឱ្យមានការទទួលយកទីតាំងថ្មី ពិតប្រាកដមែន ថែមទាំងមានការអះអាងយ៉ាងមុះមុតថា ទីតាំងដីខាងលើ គឺតែមួយ នៅភូមិអញ្ចែងលើ បន្លំឱ្យឈ្មោះ [redacted] សុខឃាង ទទួលយក ប៉ុន្តែជាក់ស្តែង ទីតាំង និងរូបរាងដី មិនដូចគ្នាទេ ហើយស្ថិតនៅភូមិអញ្ចែងលើ និងភូមិអញ្ចែងក្រោម ទៅវិញ។ បន្ថែមលើសពីនេះ ជនជាប់ចោទ មិនបានចូលខ្លួនតាមការកោះហៅរបស់តុលាការទេ បង្ហាញឱ្យឃើញថា ពិតជាមានចេតនាប្រព្រឹត្តនូវអំពើ សមគំនិតក្នុងអំពើឆបោក ខាងលើ យ៉ាងពិតប្រាកដ។

-ជនជាប់ចោទឈ្មោះ [redacted] ចន្ទូ , ឈ្មោះ [redacted] សុភា , ឈ្មោះ [redacted] លីឡេង និងឈ្មោះ [redacted] អុន ជាជនដែលមាននីតិសម្បទាគ្រប់គ្រាន់ ដោយពុំមានសញ្ញាណាមួយដែលនាំឱ្យមានមន្ទិលសង្ស័យថា ជននេះមានវិបល្លាសស្មារតីក្នុងការប្រព្រឹត្តបទល្មើសនោះទេ និងជាសមត្ថជនដែលមានការពិចារណាយល់ដឹងអំពីផលវិបាក ដែលកើតចេញពីអំពើរបស់ខ្លួន ដែលស្ថិតក្នុងលក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ហេតុនេះត្រូវតែទទួលខុសត្រូវនូវទង្វើរបស់ខ្លួនចំពោះមុខច្បាប់ព្រហ្មទណ្ឌជាធរមាន

-មានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ ដែលបញ្ជាក់ថាមានពិរុទ្ធភាពគ្រប់គ្រាន់ លើជនជាប់ចោទឈ្មោះ [redacted] ចន្ទូ ភេទប្រុស អាយុ ៤៤ឆ្នាំ ជនជាតិខ្មែរ , ឈ្មោះ [redacted] សុភា ភេទប្រុស អាយុ ៥៦ឆ្នាំ ជនជាតិខ្មែរ , ឈ្មោះ [redacted] លីឡេង ភេទប្រុស អាយុ ៧១ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] អុន ភេទប្រុស អាយុ ៥៩ឆ្នាំ ជនជាតិខ្មែរ ពីបទៈ **សមគំនិតក្នុងអំពើឆបោក** ប្រព្រឹត្តនៅភូមិអញ្ចែងលើ ឃុំពុកឬស្សី ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីអំឡុងខែវិច្ឆិកា ឆ្នាំ២០១៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩ , មាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ។



Scanned with CamScanner

-មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី តំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី បានប្តឹងទាមទារសំណងការខូចខាត និងថ្លៃសេវាមេធាវី ពីជនជាប់ចោទទាំង០៤នាក់ ចំនួន ៥ ០០០ ០០០ (ប្រាំលាន) ដុល្លារអាមេរិក។ ហេតុដូច្នេះ តុលាការនឹងពិចារណាពីសំណងរដ្ឋប្បវេណីនេះ ទៅតាមព្យសនកម្មជាក់ស្តែង។

## ហេតុដូច្នេះ វិនិច្ឆ័យសេចក្តី

១-ផ្តន្ទាទោសលើជនជាប់ចោទ ៖

១.១-ឈ្មោះ [redacted] ចន្ធូ ភេទប្រុស អាយុ ៤៤ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០២ (ពីរ)ឆ្នាំ ។

១.២-ឈ្មោះ [redacted] សុភា ភេទប្រុស អាយុ ៥៦ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០២ (ពីរ)ឆ្នាំ។

១.៣-ឈ្មោះ [redacted] លីឡេង ភេទប្រុស អាយុ ៧១ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០២ (ពីរ)ឆ្នាំ។

១.៤-ឈ្មោះ [redacted] អុន ភេទប្រុស អាយុ ៥៩ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០២ (ពីរ)ឆ្នាំ។

ពីបទៈ សមគំនិតក្នុងអំពើឆបោក ប្រព្រឹត្តនៅភូមិអញ្ចែងលើ ឃុំពុកឬស្សី ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីអំឡុងខែវិច្ឆិកា ឆ្នាំ២០១៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩, មាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

២-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] ចន្ធូ, ឈ្មោះ [redacted] សុភា, ឈ្មោះ [redacted] លីឡេង និងឈ្មោះ [redacted] អុន រួមគ្នាសងសំណងទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុខឃាង ជាប្រាក់ចំនួន ៥០០ ០០០ (ហាសិបម៉ឺន) ដុល្លារអាមេរិក ។ ការទាមទារលើសពីនេះ បដិសេធចោល។

-សាលក្រមនេះជំនុំជំរះ ជាសាធារណៈនៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈនៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០២១ កំបាំងមុខជនជាប់ចោទទាំង០៤នាក់ និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី និងចំពោះមុខមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី។

ទុកសិទ្ធិឲ្យប្តឹងទាស់ នឹងប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ ហត្ថលេខា និងត្រា** **ចៅក្រមជំនុំជម្រះ ហត្ថលេខា និងត្រា**

[redacted] [redacted]

---

(បានចម្លងត្រឹមត្រូវតាមច្បាប់ដើម)

ថ្ងៃព្រហស្បតិ៍ [illegible] ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

កណ្តាល ថ្ងៃទី០១ ខែមេសា ឆ្នាំ២០២១

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជី**

[redacted]

[illegible] ឈ្មោះ [illegible] អុន នៅថ្ងៃទី11 ខែ[illegible] ឆ្នាំ2021

មេធាវី [redacted]